BBI0089

# សម្ភាសន៍ជាមួយឈ្មោះអែម ឡាយ ភេទប្រុស អាយុ៥៨ឆ្នាំ

សព្វថ្ងៃរស់នៅភូមិស្រឡៅ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

សម្ភាសន៍ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១១

មុខងារសម័យខ្មែរក្រហមៈ កសិករ

មុខងារបច្ចុប្បន្នៈ កសិករ

សម្ភាសន៍ដោយៈ ស សេងគា

សរុបទំព័រៈ ២៥

០០:៥៥:៣៨ នាទី

សេងគាៈ ដំបូងខ្ញុំសូមជម្រាបសួរពូ ហើយខ្ញុំសូមណែនាំពូពីឈ្មោះរបស់ខ្ញុំ ខ្ញុំឈ្មោះ សេង គា ខ្ញុំអ្នកស្រុកបាត់ដំបងនេះទេ ហើយខ្ញុំនៅស្រុកឯកភ្នំនេះណា៎ ហើយខ្ញុំធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំមកសម្ភាសន៍ពូនេះ ព្រោះចង់ដឹងរឿងរ៉ាវរបស់ពូ ដែលបានឆ្លងកាត់តាំងពូតូចមករហូតដល់ធំ សង្គ្រាមរហូតចូលមកដល់បច្ចុប្បន្នហ្នឹង អញ្ចឹងបទសម្ភាសន៍ដែលខ្ញុំសម្ភាសន៍នេះគឺយក ទៅចងក្រងជាឯកសារ ហើយសម្រាប់ស្រាវជ្រាវអីផ្សេងទៀតអញ្ចឹងតើពូអត់មានថាអីទេ?

ឡាយៈ អត់មានថាអីទេ ។

សេងគាៈ អញ្ចឹងដំបូងខ្ញុំសូមស្គាល់ឈ្មោះពូ តើពូឈ្មោះអីដែរ?

ឡាយៈ ឈ្មោះ អែម ឡាយ ។

សេងគាៈ ពូអាយុប៉ុន្មានហើយ?

ឡាយៈ អាយុ៥៨ឆ្នាំ ។

សេងគាៈ មានស្រុកកំណើតនៅណាដែរ?

ឡាយៈ ស្រុកកំណើតខ្ញុំនៅភូមិព្រៃដាច់ ។

សេងគាៈ ស្រុកឯកភ្នំដែរ?

ឡាយៈ អត់ទេ ស្រុកបាត់ដំបង ស្រុកឯកភ្នំនេះគេទើបតែដាក់ទេ ។

សេងគាៈ ខ្ញុំកើតនៅស្រុកបាត់ដំបងដែរ ។ ហើយបច្ចុប្បន្ននៅក្នុងភូមិនេះដែរ ក្នុងភូមិរំដួល?

ឡាយៈ បាទ!

សេងគាៈ ពូឃុំរំដួលដែរ?

ឡាយៈ ហ្នឹងអើយ ។

សេងគាៈ ស្រុកភ្នំព្រឹកមែនពូ?

ឡាយៈ បាទ!

សេងគាៈ ហើយឪពុកពូឈ្មោះអី?

ឡាយៈ ឈ្មោះ ឡឹង ឡោ ។

សេងគាៈ គាត់ស្លាប់ហើយមែនទេ?

ឡាយៈ ស្លាប់អស់ហើយ ។

សេងគាៈ ស្លាប់តាំងពីពេលណាមក?

ឡាយៈ ស្លាប់តាំងពីខ្ញុំនៅតូច ។

សេងគាៈ សង្គមរាស្ត្រនិយមហើយមែនទេ?

ឡាយៈ បាទ!

សេងគាៈ ហើយម្ដាយឈ្មោះអី?

ឡាយៈ ម្ដាយឈ្មោះ អែម ខ្វឹង ។

សេងគាៈ អញ្ចឹងពូយកត្រកូលតាមម្ដាយ?

ឡាយៈ បាទ!

សេងគាៈ ពូមានបងប្អូនប៉ុន្មាននាក់?

ឡាយៈ ខ្ញុំមានបងប្អូន៧នាក់ ។

សេងគាៈ ហើយស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ឡាយៈ ប្រុស៤នាក់ ហើយស្រី៣នាក់ ។

សេងគាៈ ស្លាប់អស់ប៉ុន្មាននាក់?

ឡាយៈ ស្លាប់អស់៤នាក់ ។

សេងគាៈ ស្លាប់៤នាក់ហ្នឹងកាលសម័យខ្មែរក្រហម?

ឡាយៈ បាទ!

សេងគាៈ ទី១ឈ្មោះអីគេពូ?

ឡាយៈ ឈ្មោះ ឌី ។

សេងគាៈ ហើយទី២?

ឡាយៈ ឈ្មោះ លន ប្រុស ។

សេងគាៈ ហើយចុះទី៣?

ឡាយៈ ឈ្មោះ ញ៉េប ស្រី ។

សេងគាៈ ទី៤?

ឡាយៈ ទី៤ឈ្មោះ យុទ្ធ ប្រុស ។

សេងគាៈ ទី៥?

ឡាយៈ ខ្ញុំហ្នឹងឯង ។

សេងគាៈ ទី៦?

ឡាយៈ ឈ្មោះ ញ៉េម ស្រី ។

សេងគាៈ ហើយចុះទី៧?

ឡាយៈ ឈ្មោះ យឿន ។

សេងគាៈ ហើយស្លាប់នោះឈ្មោះអីខ្លះទៅ?

ឡាយៈ ឈ្មោះ ញ៉េប, ញ៉េម, ឌី, ហើយនឹង លន ។

សេងគាៈ ហើយប្រពន្ធពូឈ្មោះ ឃុយ ពៅ?

ឡាយៈ បាទ!

សេងគាៈ ហើយពូមានកូន៧នាក់ដែរ?

ឡាយៈ បាទ!

សេងគាៈ ដែលថាមានកូនឈ្មោះ ឆោម ឈឿត ហ្នឹងមែនទេ?

ឡាយៈ អាហ្នឹងបងប្អូនទេ ។

សេងគាៈ ចុះកូនទីមួយឈ្មោះអីទៅ?

ឡាយៈ ឈ្មោះ ឡុង ។

សេងគាៈ ឈ្មោះអី ឡុង,

ឡាយៈ មិនដឹងគេដាក់នាមត្រកូលអីផង ។

សេងគាៈ ហើយទី២ឈ្មោះអី?

ឡាយៈ ឈ្មោះ លឿត ។

សេងគាៈ ទី៣?

ឡាយៈ ឈ្មោះ យ៉យ ស្រី ។

សេងគា:   ទី៤?

ឡាយ:   ឈ្មោះ វិញ ស្រីដែរ ។

សេងគា:   ទី៥?

ឡាយ:   ឈ្មោះ វឿន ។

សេងគា:   ហើយចុះទី៦?

ឡាយ:   ឈ្មោះ មុំ ។

សេងគា:   ហើយចុះទី៧?

ឡាយ:   ទី៧ឈ្មោះ ពីន គេហៅវាតែអាពីនៗហ្នឹងព្រោះវាខ្មៅពេក ។

សេងគា:   ស្រីឬប្រុស?

ឡាយ:   ប្រុស ។

សេងគា:   អញ្ចឹងស្រី៣នាក់ ហើយប្រុស៤នាក់?

ឡាយ:   បាទ!

សេងគា:   អញ្ចឹងខ្ញុំចង់សួរជីវប្រវត្តិរបស់ពូកាលនៅកុមារបន្តិចសិនណា៎ពូ តើពូអាចរៀបរាប់បានទេ កាលពីពូនៅក្មេងរហូតមកដល់ឥលូវនេះ តើពូមានបានជួបការលំបាកអីខ្លះ?

ឡាយ:   ខ្ញុំកាលនៅកុមារមក ដូចថាវាអត់មានឪពុកម្តាយតាំងពីកុមារមក ។

សេងគា:   ហើយយ៉ាងម៉េចទៀតពូ?

ឡាយ:   ហើយក្រោយមកខ្ញុំបានរស់នៅជាមួយបងរហូតដល់ខ្ញុំអាយុ១៧ឆ្នាំ ដល់ពេលគេមានប្រពន្ធអស់ទៅខ្ញុំក៏នៅជាមួយប្អូនស្រី ក្រោយមកខ្ញុំក៏ដើររកស៊ី ហើយគេចេះតែតឹងតែងទៅរហូតដល់ឆ្នាំ១៩៧០ហ្នឹងខ្ញុំក៏យកកូនខ្ញុំទៅនៅជុំរុំតាកែវនៅកណ្តាលព្រៃ អាហ្នឹងជុំរុំធំណា៎ កាលហ្នឹងអត់ដឹងថាខ្មែរក្រហមផង ដល់ពេលចូលទៅនៅគឺនៅកន្លែងខ្មែរក្រហមហ្នឹងហ្មង ។

សេងគា:   ហើយយ៉ាងម៉េចទៀតពូ?

ឡាយ:   ក្រោយមកចាំខ្ញុំរៀបរាប់តាំងពីចុងឆ្នាំ៧០ហ្នឹងមក ។

សេងគា:   ពូអាចរៀបរាប់ការផ្សារពី៧០រហូតមកដល់៧៩បានទេពូ ដូចថាពូបានជួបពីណាខ្លះ ហើយពូបានធ្វើកងវរៈអីខ្លះ ហើយមានស្គាល់អ្នកណាខ្លះ ប្រធានកងឈ្មោះអីៗខ្លះ អញ្ចឹងណា៎?

ឡាយៈ ខ្ញុំមកធ្វើទ័ព ហើយមកនៅក្នុងវិវរៈតំបន់គេហ្នឹងបានតែ៣ខែទេ ហើយក្រោយមកខ្ញុំចូលទៅធ្វើ ។

សេងគា: ហើយយ៉ាងម៉េចទៀតពូ?

ឡាយៈ ហើយក្រោយមកខ្ញុំចូលទៅធ្វើកងពិសេសមជ្ឈឹមគេ ។

សេងគា: អ៎! ពូមានទៅធ្វើកងពិសេសមជ្ឈឹម?

ឡាយៈ បាទ!

សេងគា: ហើយក្រោយមកយ៉ាងម៉េចទៀតពូ?

ឡាយៈ ដល់ហើយចូលឆ្នាំ៧៥ហ្នឹង ។

សេងគា: ហើយបន្ទាប់មកទៀត?

ឡាយៈ ក្រោយមកគេធ្វើប្រវត្តិរូប ។

សេងគា: ឆ្នាំ៧៥ហ្នឹងគេធ្វើប្រវត្តិរូប?

ឡាយៈ អត់ទេ ឆ្នាំ៧៦ គេធ្វើហ្នឹងដូចថាយើងជាប់ទិន្នាការធ្វើទាហានមុនៗមកហ្នឹងណា៎ ហើយខ្ញុំនឹកឃើញថាខ្ជិលព្រោះបងប្អូនខ្ញុំគេសម្លាប់ទាំងអស់គ្នាហើយ ដល់ហើយខ្ញុំដាក់ប្រវត្តិខ្ញុំធ្វើទាហានហ្មងទៅ ហើយគេក៏ដកខ្ញុំចេញមកនៅថ្មគោលនេះ ។

សេងគា: ហើយយ៉ាងម៉េចទៀតពូ?

ឡាយៈ មកនេះរហូតហ្នឹង ខ្ញុំមកនៅជួសជុលនៅហ្នឹងរហូត ទទួលឆ្នាំដែលនារតីចូលមកគេជម្លៀសខ្ញុំចេញទៅ៧ខែបានយួនចូលមក ហើយមនុស្សក៏បែកបាក់គ្នាអស់ទៅ ។

សេងគា: ពូកាលពីកុមារពូមានរៀនខ្លះទេ?

ឡាយៈ ខ្ញុំនៅតែវត្តទេ ។

សេងគា: រៀនសាលានៅវត្តមែន?

ឡាយៈ បាទ!

សេងគា: ហើយពូពីតូចពូនៅវត្តទេ?

ឡាយៈ បាទ! ក្រោយពេលដែលឪពុកខ្ញុំគាត់ខូចទៅខ្ញុំទៅនៅវត្តបាន២ឆ្នាំ អត់មានបានបួសបានរៀនអីទេ ។

សេងគា: អញ្ចឹងធ្វើកូនសិស្សលោក អាហ្នឹងឆ្នាំប៉ុន្មានឆ្នាំ?

ឡាយៈ អត់ចាំទេ ។

សេងគា: អាយុបានប្រហែលជា... ។

ឡាយៈ អាយុបានប្រហែលជា៧-៨ឆ្នាំហ្នឹង ។

សេងគាៈ អាយុបានប្រហែលជា៧-៨ឆ្នាំហ្នឹង ។

ឡាយៈ វត្តដែលពូនៅហ្នឹងឈ្មោះ វត្តឯកភ្នំ ។

សេងគាៈ ហើយធ្វើកូនសិស្សលោកឈ្មោះអីទៅ?

ឡាយៈ នៅជាមួយអធិការ ឡុង ។

សេងគាៈ ហើយក៏ដាក់ ឡុង ទៅ?

ឡាយៈ ឡុង ហ្នឹងព្រះនាមរបស់លោក ។

សេងគាៈ អ៊ំ! ឈ្មោះ ឡុង ហើយនៅជាមួយលោកបាន២ឆ្នាំហ្នឹងមានបានរៀនបានសូត្រទេ?

ឡាយៈ រៀនអក្សរ ។

សេងគាៈ ហើយពូអាចអានអក្សរបានទេ?

ឡាយៈ មើលបានខ្លះ តែឥលូវងងឹតហើយសូម្បីតែសរសេរហ្នឹងក៏មិនបានដែរ ។

សេងគាៈ ហើយពីមុនមើលបាន?

ឡាយៈ បាន ។

សេងគាៈ ហើយបន្ទាប់ពីហ្នឹងមកពូទៅណាទៀត?

ឡាយៈ មកនៅជាមួយបងវិញ ។

សេងគាៈ នៅជាមួយបងណា?

ឡាយៈ នៅជាមួយបងស្រីដែលថាស្លាប់ឈ្មោះ ញ៉ៀន ហ្នឹង ។

សេងគាៈ នៅជាមួយគាត់រហូតដល់អាយុ១៧ឆ្នាំ?

ឡាយៈ បាទ!

សេងគាៈ ដល់ពេល១៧ឆ្នាំហ្នឹងឆ្នាំ៧០គត់មែន?

ឡាយៈ មិនមែនទេគឺឆ្នាំ៦៨-៦៩-៧០ ប្រហែលជា៦៨ហ្នឹងហើយ ។

សេងគាៈ ចុះ៧០?

ឡាយៈ ឆ្នាំ៧០ខ្ញុំទៅធ្វើខ្មែរក្រហមហើយ ។

សេងគាៈ ចុះពេលនៅជាមួយបងដល់ឆ្នាំ៦៨ ហើយបន្ទាប់មកធ្វើអីទៀត?

ឡាយៈ មានធ្វើអី ខ្ញុំទៅធ្វើខ្មែរក្រហម ។

សេងគាៈ ហេតុអីបានជាឈប់នៅជាមួយបង?

ឡាយៈ ពិបាកនៅក្នុងគ្រួសារណាស់ ។

សេងគាៈ គាត់មានគ្រួសារហើយ?

ឡាយៈ គាត់មានហើយ ។

សេងគាៈ ដល់ពេលអញ្ចឹងទៅក៏សម្រេចចិត្តទៅធ្វើខ្មែរក្រហម?

ឡាយៈ បាទ!

សេងគាៈ ហើយទៅធ្វើខ្មែរក្រហមនៅណា៎?

ឡាយៈ ដំបូងខ្ញុំនៅព្រៃធំ ។

សេងគាៈ ទៅនៅព្រៃធំ?

ឡាយៈ ហ្នឹងអើយព្រៃធំយើងនេះ ។

សេងគាៈ តែកាលហ្នឹងគេមិនទាន់បញ្ជូនទៅថ្មគោលទេ?

ឡាយៈ នូវទេ ។

សេងគាៈ ដល់ពេលអញ្ចឹងក៏ធ្វើទាហាន?

ឡាយៈ បាទ!

សេងគាៈ ១៩៦៩ពូធ្វើទាហាន?

ឡាយៈ បាទ!

សេងគាៈ ធ្វើទាហានអីគេកាលហ្នឹង ទាហានខ្មែរក្រហមមែន ឬក៏ទាហាន លន់ នល់?

ឡាយៈ កាលហ្នឹងធ្វើទាហាន លន់ នល់ ។

សេងគាៈ គេមកចាប់ឬក៏ធ្វើទាហានខ្លួនឯង?

ឡាយៈ គេតម្រូវអញ្ចឹងហើយ ។

សេងគាៈ កាលហ្នឹងពីណាជាអ្នកតម្រូវ?

ឡាយៈ មេភូមិឈ្មោះ ឆួង ។

សេងគាៈ គាត់ចាត់ឲ្យធ្វើទាហានមែន?

ឡាយៈ បាទ!

សេងគាៈ នៅព្រៃធំ?

ឡាយៈ អត់ទេ អាហ្នឹងទាហាន លន់ នល់ ។

សេងគាៈ អញ្ចឹងធ្វើទាហាននៅណាទៅ?

ឡាយៈ ធ្វើទាហាននៅវាលបែកចាន អាហ្នឹងទាហានខាង លន់ នល់ ណា៎ ។

សេងគាៈ វាលបែកចាននៅបាត់ដំបងណោះ?

ឡាយៈ បាទ!

សេងគាៈ ហើយចាត់ធ្វើហ្នឹង ធ្វើគ្នាប៉ុន្មាននាក់ទៅ?

ឡាយៈ ធ្វើទាំងភូមិ ឲ្យតែនៅលីវគឺត្រូវតែទៅធ្វើ ។

សេងគាៈ អញ្ចឹងឲ្យតែលីវទៅធ្វើទាំងអស់?

ឡាយៈ បាទ!

សេងគាៈ ហើយពេលដែលទៅដល់កន្លែងបន្ទាយហ្នឹងពូទៅកងមួយណាទៅ នៅក្នុងវរៈមួយណាទៅ?

ឡាយៈ ខ្ញុំនៅជាមួយលោក មាស ។

សេងគាៈ លោក មាស ហ្នឹងគាត់ធ្វើអីគេ?

ឡាយៈ គាត់ស័ក្តមួយ គាត់ក្តាប់នៅហ្នឹងផ្ទាល់ ហើយមិនស្គាល់មេក្រុមមេអីស្រួលបួលផងគាត់ចេញទៅបាត់ហើយ ។

សេងគាៈ គាត់ស័ក្តមួយហ្នឹងកាន់ខាងអីគេពូ?

ឡាយៈ គាត់កាន់ខាងកាប៉ាញី ។

សេងគាៈ កាប៉ាញីហ្នឹងអីគេ?

ឡាយៈ ទាហានគេហៅថាកាប៉ាញី ។

សេងគាៈ អញ្ចឹងគាត់កាន់ខាងកាប៉ាញី?

ឡាយៈ បាទ!

សេងគាៈ ហើយកាប៉ាញីហ្នឹងមានកូនទាហានប៉ុន្មាននាក់?

ឡាយៈ មាន៣០០នាក់ ។

សេងគាៈ មានទាហាន៣០០នាក់ អាហ្នឹងស្មើរហ្នឹងកងវរយទេ?

ឡាយៈ ស្មើរហ្នឹងវរៈសេនាតូច ។

សេងគាៈ អញ្ចឹងពូនៅជាមួយលោក មាស ហ្នឹង?

ឡាយៈ បាទ!

សេងគាៈ ហើយបន្ទាប់ពីហ្នឹងមក ទៅហាត់ទាហានបានប៉ុន្មានថ្ងៃទៅ?

ឡាយៈ បានតែ៦-៧ថ្ងៃគេប្រុងបញ្ជូនទៅខ្ញុំរត់មកតែម្តងទៅ ។

សេងគាៈ ហាត់បាន៦-៧ថ្ងៃគេប្រុងបញ្ជូនពូទៅណា?

ឡាយៈ ប្រុងបញ្ជូនទៅយួន ។

សេងគា:	ហើយម៉េចបានពូដឹងថាគេបញ្ជូន?

ឡាយ:	ដឹង ។

សេងគា:	គេប្រាប់?

ឡាយ:	ហ្នឹងអើយ ។

សេងគា:	កាលហ្នឹងគេប្រជុំប្រាប់?

ឡាយ:	បាទ!

សេងគា:	ហើយដល់អញ្ចឹងទៅពូរត់ទៅណា?

ឡាយ:	ខ្ញុំរត់ចេញមកវិញទៅហ្នឹងហ្នង ទៅធ្វើខ្មែរក្រហម ។

សេងគា:	រត់ចេញពីបន្ទាយទៅវាលបែកចានហ្នឹងមែន?

ឡាយ:	បាទ!

សេងគា:	រត់ចេញពីបន្ទាយបែកចានហ្នឹងចេញទៅណាវិញទៅ?

ឡាយ:	នៅផ្ទះបានប្រហែលជា២-៣ខែដែរ ហើយគេតាមរកខ្ញុំទៅធ្វើខ្មែរក្រហមទៅ ។

សេងគា:	ហើយមកនៅស្រុកឯកភ្នំវិញ?

ឡាយ:	មកនៅស្រុកបាត់ដំបងនេះ ។

សេងគា:	ហើយនៅផ្ទះបានប្រហែលជា៣-៤ខែ?

ឡាយ:	បានប្រហែលជាប៉ុណ្ណឹងហើយ ហើយគេតាមរកខ្ញុំក៏ទៅធ្វើខ្មែរក្រហមទៅ ។

សេងគា:	អ្នកណាគេអ្នកមកតាមរក?

ឡាយ:	មេគេប្រើឲ្យកូនទាហានមកតាមរក ។

សេងគា:	ហើយពូក៏ចេញពីហ្នឹងទៅ?

ឡាយ:	បាទ!

សេងគា:	រត់ចេញពីផ្ទះហ្នឹងមកសំដៅទៅណា សំដៅទៅព្រៃហ្នឹងមែន?

ឡាយ:	មកព្រៃ ។

សេងគា:	មកព្រៃធំហ្នឹងមែន?

ឡាយ:	បាទ!

សេងគា:	ហើយក៏ធ្វើជាទាហានខ្មែរក្រហម?

ឡាយ:	បាទ!

សេងគា:	កាលហ្នឹងពូចូលកងមួយណា ហើយពីណាគេជាប្រធាន?

ឡាយៈ ប្រធានឈ្មោះ ណាំ ។

សេង៉គាៈ វរៈសេនាធំឬក៏វរៈសេនាតូចកាលហ្នឹង?

ឡាយៈ វរៈសេនាតូច ។

សេង៉គាៈ ហើយកាលហ្នឹងកង៉ពលលេខប៉ុន្មានដែរ កាលហ្នឹងមានកង៉ពលទេ?

ឡាយៈ អត់ទាន់មានទេ ។

សេង៉គាៈ អត់ទាន់មានទេ មានតែកង៉វរៈ ។ ហើយចុះកង៉វរៈសេនាធំឈ្មោះអីទៅ?

ឡាយៈ មានតែ រស់ ញឹម ហ្នឹងអ្នកកាន់កាប់ ។

សេង៉គាៈ រស់ ញឹម គាត់អ្នកក្តាប់ទាំងអស់?

ឡាយៈ បាទ! ហើយគាត់ជាប្រធានភូមិភាគផង ។

សេង៉គាៈ ហើយវរៈសេនាតូចមានប្រហែល៣០០នាក់?

ឡាយៈ មាន៣០០នាក់ ។

សេង៉គាៈ ហើយកាលពូរត់ហ្នឹងពូរត់មកតែឯង ឬក៏រត់មកជាមួយពីណាគេ?

ឡាយៈ មកតែឯងទេ ។

សេង៉គាៈ ពូចេះតែរត់ ឬក៏មានដឹងដំណឹងថាកន្លែងហ្នឹងមានទាហាន បានរត់មក?

ឡាយៈ អត់មានដឹងទេ ។

សេង៉គាៈ អញ្ចឹងពូចេះតែរត់ទៅ?

ឡាយៈ បាទ! អាហ្នឹងដូចថាយើងចេះតែគេចៗខ្លួនទៅណា៎ ។

សេង៉គាៈ ដល់ពេលគេចខ្លួនមកដល់កន្លែងហ្នឹង គេហៅពូធ្វើឬក៏ចង់ធ្វើខ្លួនឯង?

ឡាយៈ គ្រាន់តែចូលមកដល់កន្លែងហ្នឹងហើយ មានអ្នកអប់រំខ្ញុំ ។

សេង៉គាៈ អ្នកណាគេអ្នកអប់រំ?

ឡាយៈ មិនបានស្គាល់ឈ្មោះគេទេ ។

សេង៉គាៈ អប់រំថាយ៉ាងម៉េចទៅ?

ឡាយៈ គ្រាន់តែអប់រំឲ្យយើងធ្វើគ្រាប់ធ្វើអីហ្នឹង ។

សេង៉គាៈ កាលពូមកដល់ភ្លាមគេនៅក្នុងភូមិអីទៅ?

ឡាយៈ ខ្ញុំនៅជិរុំតាកែវ ។

សេង៉គាៈ រត់មកពីផ្ទះមកនៅជិរុំតាកែវ?

ឡាយៈ បាទ!

សេងគាៈ កាលរត់មកជិះអីមក?

ឡាយៈ ជិះរទេះសេះ ។

សេងគាៈ ជួលគេមកមែនពូ?

ឡាយៈ ជួល ។

សេងគាៈ អញ្ចឹងមកជំរុំ?

ឡាយៈ បាទ!

សេងគាៈ ហើយជំរុំតាកែវនៅកន្លែងណាវិញពូ?

ឡាយៈ ជំរុំតាកែវនៅខាងកើតព្រៃធំ ។

សេងគាៈ ព្រៃធំនៅភូមិអីគេ?

ឡាយៈ អត់ដឹងនៅភូមិអីទេ ដឹងតែគេហៅថាព្រៃធំៗ ។

សេងគាៈ ហើយឃុំអី?

ឡាយៈ ប្រហែលជាឃុំប្រដាក ។

សេងគាៈ ហើយស្រុកអីគេ?

ឡាយៈ ស្រុកបាត់ដំបង ។

សេងគាៈ ជំរុំតាកែវហ្នឹងជាជំរុំយ៉ាងម៉េចទៅពូ?

ឡាយៈ គេដាក់តែឈ្មោះ ព្រោះកន្លែងហ្នឹងគេចាប់ចងតែពួកអ្នកតាកែវ ដល់ពេលអញ្ចឹងគេហៅជំរុំតាកែវហ្នុងទៅ ។

សេងគាៈ អ្នកចាប់ចងកន្លែងហ្នឹងសំបូរអ្នកតាកែវ?

ឡាយៈ បាទ!

សេងគាៈ កាលហ្នឹងពួកតាកែវមកនៅកន្លែងហ្នឹងច្រើនទេ?

ឡាយៈ នៅតិចដែរទេ នៅរាយៗហ្នឹង មនុស្សប្រហែលជា២០គ្រួសារ ។

សេងគាៈ កាលពូមកនៅមានឃើញទ័ពច្រើនទេកាលហ្នឹង?

ឡាយៈ កាលហ្នឹងឃើញតែទ័ពតំបន់មួយវរៈហ្នឹងឯង ។

សេងគាៈ ហើយ រស់ ញឹម អីអត់មានដែលដឹងទេ?

ឡាយៈ គាត់អត់មាននៅហ្នឹងទេ កន្លែងគាត់អត់មានអ្នកណាចូលបានទេ ។

សេងគាៈ ហើយនៅហ្នឹងមានលោកជាអ្នកដឹកនាំទៅ?

ឡាយៈ បាទ!

សេង៍គា៖ ហើយពេលដែលចូលហ្នឹងគេមានសួរនាំអីទេ ហើយកាលទៅហ្នឹងជិះរទេះសេះប៉ុន្មានថ្ងៃប៉ុន្មានខែដែរបានគេឲ្យចុះឈ្មោះចូលធ្វើទាហានហ្នឹង?

ឡាយ៖ ទៅនៅបានប្រហែលជា៣ខែ ។

សេង៍គា៖ ទៅនៅបាន៣ខែគេក៏អប់រំយើងឲ្យចូលធ្វើជាទាហានទៅ?

ឡាយ៖ បាទ!

សេង៍គា៖ ហើយចូលធ្វើទាហានមុនដំបូងពូបានដំណែងជាកូនទាហានធម្មតាទេ?

ឡាយ៖ កូនទាហានធម្មតា ។

សេង៍គា៖ ហើយពូមានបានឡើងឋានៈអីទៀតទេកាលហ្នឹង?

ឡាយ៖ អត់មានទេ ព្រោះយើងនៅបាន២-៣ខែអត់មានបានដំណែងទេ ដល់ក្រោយមកបានចេញពីហ្នឹងមក ។

សេង៍គា៖ ហើយពេលនៅហ្នឹងបាន២-៣ខែ គេមានឲ្យទៅហាត់ទាហានហាត់អីទេ?

ឡាយ៖ អត់មានហាត់ទេខ្មែរក្រហម ។

សេង៍គា៖ ឲ្យកាន់កាំភ្លើងយកតែម្ដង?

ឡាយ៖ បាទ! បើគេប្រាប់យើងថាដាំបាយអីហ្នឹងរហ័ស តែមិនមែនទេគឺគេយកយើងទៅវ៉ៃចោល ដាំបាយហើយគេយកទៅវ៉ៃចោលតែម្ដង ។

សេង៍គា៖ ពូមានធ្លាប់វ៉ៃជាមួយទាហាន លន់ នល់ ញឹកញាប់ទេ?

ឡាយ៖ តាំងពីហ្នឹងមកទល់ឆ្នាំ៧៥ក្រាស់ដែរហ្នឹង វ៉ៃរហូតឆ្ពាយដល់សៀមរាបនោះហ្នឹង ។

សេង៍គា៖ អ៎! ពូមានវ៉ៃទៅដល់សៀមរាបដែរ?

ឡាយ៖ បាទ!

សេង៍គា៖ អញ្ចឹងពូរត់ចូលជំរុំតាកែវនៅឆ្នាំ៦០ជាងទេ?

ឡាយ៖ បាទ!

សេង៍គា៖ ហើយចូលទាហាន លន់ នល់ រហូតដល់?

ឡាយ៖ ធ្វើបានតែប៉ុន្មានថ្ងៃហ្នឹង កាលរដ្ឋប្រហារហ្នឹងវាមិនទាន់ចូលដល់ឆ្នាំ៧០ទេ វានៅចុងឆ្នាំ៦៩ ។

សេង៍គា៖ អញ្ចឹងពូចេញពីទ័ពបានតែ២-៣ខែទេ ហើយកាលហ្នឹងឆ្នាំ៦៨ ហើយកាលហ្នឹងនៅផ្ទះបានតែ៣ខែក៏រត់មកចូលនេះទៅ រត់មកចូលព្រៃជាមួយខ្មែរក្រហមទៅ?

ឡាយ៖ បាទ!

សេងគា: អញ្ចឹងពី៧០ មករហូតដល់ឆ្នាំ៧៥ បាន៥ឆ្នាំ ។ តើពូអាចរៀបរាប់ពីកន្លែងដែលពូធ្វើទាហាននៅជុំវិញតាកែវហ្នឹងបានទេ ធ្វើទ័ពហ្នឹងហាត់បានប៉ុន្មានថ្ងៃ ហើយធ្វើទ័ពហ្នឹងអត់មានបានឡើងឋានៈអីទេ?

ឡាយៈ ខ្ញុំនៅធ្វើទ័ពជាមួយ ណាំ ហ្នឹងបានតែ៣ខែទេ ហើយក្រោយមកគេបញ្ជូនទៅមជ្ឈិមផ្សេងទៅ ។

សេងគា: ហើយដល់ពេលឆ្នាំ៧០ គេបញ្ចូលជាកងមជ្ឈិម?

ឡាយៈ បាទ! ហើយគេបញ្ចូលទៅមជ្ឈិមផ្សេងហ្នឹងក៏អត់មានបានហាត់រៀនដែរ នៅតែជាមួយសេនាធិការគេហ្នឹង ។

សេងគា: សេនាធិការឈ្មោះ ណាំ ហ្នឹងមែន?

ឡាយៈ អត់ទេ ។

សេងគា: ឈ្មោះអីគេ?

ឡាយៈ ឈ្មោះ រិទ្ធ ។

សេងគា: សេនាធិការហ្នឹងមានន័យថាយ៉ាងម៉េចទៅ?

ឡាយៈ សេនាធិការគឺមេទ័ព មេទ័ពតពី រស់ ញឹម ។

សេងគា: ហើយពូទៅនៅជាមួយគាត់ផ្ទាល់?

ឡាយៈ នៅកន្លែងហ្នឹង ។

សេងគា: ហើយម៉េចបានជាពូដូរចេញពី តាណាំ ហ្នឹង?

ឡាយៈ គេតម្រូវឲ្យទៅ ។

សេងគា: ហើយនៅជាមួយ រិទ្ធ ហ្នឹងរហូតទៅ?

ឡាយៈ បាទ!

សេងគា: រិទ្ធ ហ្នឹងគេដូរបន្ទាយពីតាកែវទៅណាវិញ?

ឡាយៈ រិទ្ធ ហ្នឹងមិនទៀងព្រោះគាត់មេបញ្ជាការរួម គាត់បន្ទាប់ពី រស់ ញឹម មក ។

សេងគា: អញ្ចឹងពូចេញពីកន្លែងណាខ្លះ ពូអាចរៀបរាប់ពីដំណាក់មួយៗបានទេ?

ឡាយៈ ភាគច្រើននៅតែម្តុំព្រៃធំ ។

សេងគា: នៅម្តុំព្រៃធំហើយទៅណាទៀត?

ឡាយៈ ចេញពីហ្នឹងមកគេបញ្ជូនឲ្យទៅវ៉ៃ ហើយពួកខ្ញុំគេមិនសូវប្រើប្រាស់ទេ ព្រោះមនុស្សវាតិច ។

សេងគា៖ មានមនុស្សប៉ុន្មាននាក់ទៅនៅក្នុងកងហ្នឹង?

ឡាយ៖ មានតែប្រហែលជា៣០នាក់ហ្នឹង បើទ័ពពិសេសគេមិនសូវប្រើទេ។

សេងគា៖ ទាល់តែចាំបាច់បានប្រើ?

ឡាយ៖ បាទ! ទាល់តែសត្រូវចូលវ៉ៃក្នុងបន្ទាយបានគេប្រើ។

សេងគា៖ ពិសេសហ្នឹងមានន័យថាអ្នកហ្នឹងសុទ្ធតែគេចំរាញ់ហើយ?

ឡាយ៖ បាទ!

សេងគា៖ ហើយអ្នកខ្លាំងៗហ្នឹងទាល់តែករណីពិសេសបានគេប្រើ បើធម្មតាគេឲ្យទាហានធម្មតាទៅទេ?

ឡាយ៖ ហ្នឹងអើយ គេឲ្យយើងទៅជាមួយគេធម្មតាអញ្ចឹងទៅ តែគេមិនឲ្យយើងចូលត្រៀមជាមួយគេទេ ទៅដូចថាអ្នកត្រៀមគេនៅអូរព្រំដែនអញ្ចឹងទៅ យើងនៅនេះ នៅចាំមើលដូចថាគេស្រែកថាជួយផងពួកហ្នឹងបាក់ហើយ អាហ្នឹងបានទៅ បើថាអត់បាក់ទេយើងនៅនេះទៅ។

សេងគា៖ ខ្ញុំចង់ដឹងពីលក្ខណៈទ័ពពិសេសបន្តិច ទាល់តែអ្នកហ្នឹងយ៉ាងម៉េចទៅបានគេហៅថាទ័ពពិសេស?

ឡាយ៖ អាហ្នឹងបើនិយាយពីជំនាន់ខ្មែរក្រហមគេហៅថាកម្មាភិបាល គេយកពួកកម្មាភិបាលទៅរួមគ្នាធ្វើជាកងទ័ពមួយក្រុមហ្នឹង។

សេងគា៖ ហើយពូកាលហ្នឹងកម្មាភិបាលដែរ?

ឡាយ៖ គេទើបតែបញ្ចូល ដល់ពេលគេបញ្ចូលគេដកទៅហ្នឹង។

សេងគា៖ កាលហ្នឹងគេបញ្ចូលជាកម្មាភិបាល?

ឡាយ៖ បាទ!

សេងគា៖ កម្មាភិបាលមានឋានៈជាស្អីទៅ?

ឡាយ៖ អាហ្នឹងវាអត់ទៀង វានៅក្នុងជួរ អាហ្នឹងវាមានជនត្រៀម ជនបម្រើន ពួកសម្ព័ន្ធ អាហ្នឹងគេដកយកតែពួកសម្ព័ន្ធទេ។

សេងគា៖ ហើយពូចូលក្នុងពួកសម្ព័ន្ធ?

ឡាយ៖ បាទ!

សេងគា៖ ហើយមានអីទៀតទៅពូ?

ឡាយ៖ អត់មានទេ បក្សយើងមិនអាចឈានទៅដល់ទេ។

សេងគា៖	អញ្ចឹង?
ឡាយ៖	និយាយម៉ាត្រឹមកន្លែងយើងទៅ ។
សេងគា៖	ហើយមានជនបក្ស?
ឡាយ៖	បក្សហ្នឹងផ្សេងមួយទៀត អាហ្នឹងបក្សគេកម្រិតលើហ្នឹងទៀត ។
សេងគា៖	អញ្ចឹងទាល់តែកងទ័ពធម្មតាបានចូលចម្រើន?
ឡាយ៖	បាទ!
សេងគា៖	ជនចម្រើនហើយបានជនសម្ព័ន្ធ?
ឡាយ៖	បាទ!
សេងគា៖	ហើយពូចូលដល់ជនចម្រើនហើយចូលដល់ជនសម្ព័ន្ធ?
ឡាយ៖	បាទ! ចូលដល់ជនសម្ព័ន្ធ ។
សេងគា៖	គេបញ្ជូនទៅហ្នឹងហ្មង?
ឡាយ៖	បាទ!
សេងគា៖	អញ្ចឹងទ័ពពិសេសទាំងប៉ុន្មានសុទ្ធតែចូលដល់ជនសម្ព័ន្ធទាំងអស់?
ឡាយ៖	អាហ្នឹងបានគេយក ។
សេងគា៖	ឥលូវឧទាហរណ៍ថាពូនៅក្នុងព្រៃធំហ្នឹងទេ ហើយបន្ទាប់មកទៀតពូទៅណាទៀត?
ឡាយ៖	នៅវិលវិលវល់ៗហ្នឹងទៅ ។
សេងគា៖	ហើយចុះពូថាទៅដល់សៀមរាបនោះ?
ឡាយ៖	ទៅសៀមរាបហ្នឹងយូៗ គេយកទៅម្តងហ្នឹង ។
សេងគា៖	ហើយទៅជិះអីទៅ ជិះឡានទៅមែន?
ឡាយ៖	ដើរទៅ ។
សេងគា៖	ដើរទៅ ដល់ពេលទៅដល់ព្រៃធំហើយទៅសៀមរាប?
ឡាយ៖	បាទ! ដើរពីហ្នឹងទៅសៀមរាប ។
សេងគា៖	ប៉ុន្មានខែ ប៉ុន្មានឆ្នាំបានគេខ្ទីទៅម្តង?
ឡាយ៖	ទេ កាលដែលខ្ញុំចូលហ្នឹងគេខ្ទីទៅម្តង ។
សេងគា៖	ខ្ទីកាលឆ្នាំណា?
ឡាយ៖	ខ្ទីឆ្នាំ៧៣ ។
សេងគា៖	អញ្ចឹងដល់ពេលទៅវៃ ហើយឈ្នះបកមកវិញទៅ?

ឡាយៈ បាទ!

សេងគាៈ ហើយវៃហ្នឹងវៃរយៈពេលប៉ុន្មានខែ?

ឡាយៈ វៃបានតែមួយអាទិត្យហ្នឹង ។

សេងគាៈ វៃទាល់តែឈ្នះបានមកវិញ?

ឡាយៈ វៃទាល់តែបែក ។

សេងគាៈ កាលហ្នឹងវៃនៅបន្ទាយណា នៅបន្ទាយសៀមរាបមែន?

ឡាយៈ វៃនៅវត្តជ្រោយធ្នួន ។

សេងគាៈ ទាហានខាងជ្រោយធ្នួនហ្នឹងខ្លាំងមែន?

ឡាយៈ ខ្លាំង ។

សេងគាៈ ទាល់តែវៃបែកបានមកបន្ទាយហ្នឹងមែន?

ឡាយៈ បាទ!

សេងគាៈ ហើយទាហាន លន់ នល់ គេចាប់ធ្វើអីដែរកាលហ្នឹង សម្លាប់ចោលឬក៏យកទៅធ្វើអី?

ឡាយៈ ទេ កាលហ្នឹងអត់ទាន់មានហេតុការណ៍ហ្នឹងផង ។

សេងគាៈ គេអត់ទាន់សម្លាប់ទេ?

ឡាយៈ គ្រាន់តែវៃបែក ។

សេងគាៈ ដល់ពេលវៃបែកហើយគេសារភាពទៅ អត់មានធ្វើបាបអីទេ?

ឡាយៈ អត់មានទេ ។

សេងគាៈ ហើយបន្ទាប់មកដើរមកវិញ?

ឡាយៈ បាទ!

សេងគាៈ អញ្ចឹងនៅក្នុងព្រៃធំរហូតដល់ឆ្នាំ៧៥ ?

ឡាយៈ ហ្នឹងអើយ ។

សេងគាៈ បន្ទាប់ពី៧៥មក ពួទៅណាទៀត?

ឡាយៈ ពីត្រឹមហ្នឹងដូចចប់ហើយ ។

សេងគាៈ ដល់ហើយគេឡូពួទៅណា?

ឡាយៈ បន្ទាប់មកខ្ញុំមកនៅគោក ។

សេងគាៈ ភូមិគោក ហើយចុះឃុំ?

ឡាយៈ អត់ស្គាល់ទេ ។

សេងគាៈ ហើយស្រុក?

ឡាយៈ មិនដឹងនៅក្នុងស្រុកអី ប្រហែលជានៅក្នុងស្រុកអង្គរបុរីក៏មិនដឹង ។

សេងគាៈ កាលហ្នឹងខេត្តបាត់ដំបងដែរ?

ឡាយៈ ខេត្តបាត់ដំបង ។

សេងគាៈ ពេលដែលពូមកនៅហ្នឹងគេចាត់កម្លាំងឲ្យមកនៅខ្សែត្រៀមហ្នឹងមែនពូ?

ឡាយៈ គេឲ្យមកនៅ ។

សេងគាៈ អាហ្នឹងចុង៧៥ហើយមែនទេ?

ឡាយៈ ចុងឆ្នាំ៧៥ ។

សេងគាៈ ដល់ពេលគេឲ្យមកនៅអញ្ចឹង មកនៅយ៉ាងម៉េចទៅ?

ឡាយៈ មកនៅធម្មតា ។

សេងគាៈ ម៉េចបានជាគេឲ្យនៅហ្នឹង?

ឡាយៈ កន្លែងណាលំបាកគឺត្រូវតែឲ្យមកនៅ ។

សេងគាៈ អញ្ចឹងកន្លែងនេះលំបាកបានគេឲ្យមកនៅ?

ឡាយៈ បាទ!

សេងគាៈ មកដឹកនាំដោយមេរបស់ពូទៅ?

ឡាយៈ បាទ!

សេងគាៈ ប្រធានឈ្មោះ រិទ្ធ ហ្នឹងមែន?

ឡាយៈ ហ្នឹងអើយ ។

សេងគាៈ ហើយមួយកងចល័តពិសេសរបស់ពូហ្នឹងមានអ្នកណាគេស្លាប់នឹងរបួសអីទេ?

ឡាយៈ ស្លាប់សឹងតែទាំងអស់ ។

សេងគាៈ នៅសល់ប្រហែលជាប៉ុន្មាននាក់ទៅ?

ឡាយៈ បើតាមខ្ញុំស្តាប់ទៅពួកគេថា នៅសល់តែម្នាក់ហ្នឹង ។

សេងគាៈ នៅសល់អ្នកណាគេ?

ឡាយៈ នៅសល់ កែ ហន រស់នៅប៉ៃលិន ។

សេងគាៈ កែ ហន?

ឡាយៈ បាទ! នៅសល់តែមួយហ្នឹងឯង ក្រៅពីហ្នឹងអត់មានពួកឈ្មោះអ្នកណាទៀតទេ ។

សេងគាៈ កែ ហន ហ្នឹងជាមួយពូដែរកាលហ្នឹង?

ឡាយៈ បាទ!

សេងគាៈ កាលហ្នឹងនៅទ័ពជាមួយមានពីណាគេខ្លះ មាន កែ ហន ហើយមានអ្នកណាទៀត?

ឡាយៈ បញ្ជាការគេចាប់នៅជំនាន់ឆ្នាំប៉ុន្មានទេ ហើយ កែ ហន ហ្នឹងកូនទាហានដូចខ្ញុំដែរហ្នឹង ។

សេងគាៈ ហើយចុះកូនទាហានផ្សេងទៀត?

ឡាយៈ កូនទាហានផ្សេងទៀតអត់មានឈ្មោះទេ ហើយបញ្ជាការមានឈ្មោះ នឿន មួយ មេបញ្ជាការកងតូចហ្នឹង ហើយមានឈ្មោះ វឿន មួយប៉ុន្តែអត់ដែលមានព្រួដំណឹងទេ ។

សេងគាៈ ហើយពូនៅភូមិគោកនិមិត្តបានប្រហែលជាប៉ុន្មានឆ្នាំ?

ឡាយៈ នៅបានប្រហែលជា២ខែហ្នឹង គេដកខ្ញុំមកឈប់ឲ្យនៅ ។

សេងគាៈ នៅបានប្រហែលជា២ខែ ហើយគេដកទៅណាទៅ?

ឡាយៈ ដកមកនៅថ្មគោល ។

សេងគាៈ ពីណាគេអ្នកដក?

ឡាយៈ មេបញ្ជាការគេដក ។

សេងគាៈ រិទ្ធ ហ្នឹងមែន?

ឡាយៈ បាទ!

សេងគាៈ ម៉េចបានគេដកឲ្យមកនៅហ្នឹងវិញ?

ឡាយៈ ដាប់ប្រវត្តិគ្នា ។

សេងគាៈ អញ្ចឹងគេដកឲ្យមកនៅហ្នឹងវិញឆ្នាំ៧៦ហើយ?

ឡាយៈ បាទ!

សេងគាៈ ចុះពូនៅថ្មគោលគេឲ្យពូធ្វើអី?

ឡាយៈ ខ្ញុំគេឲ្យមើលការខុសត្រូវផ្នែកជួសជុលកសិកម្ម ។

សេងគាៈ ប្រធានផ្នែកកសិកម្ម ឬក៏ប្រធានផ្នែកជួសជុល?

ឡាយៈ ប្រធានខាងផ្នែកជួសជុល ខាងកសិកម្មប្រធានគេផ្សេង ។

សេងគាៈ ជួសជុលគ្រឿងម៉ាស៊ីនមែន?

ឡាយៈ បាទ!

សេងគាៈ ជួសជុលគ្រឿងម៉ាស៊ីននៅថ្មគោល គ្រឿងម៉ាស៊ីនហ្នឹងនៅក្នុងមន្ទីរកសិកម្ម?

ឡាយៈ បាទ!

សេងគាៈ ម៉េចបានជាគេឲ្យពូកាន់ខាងជួសជុលអញ្ចឹង ពូចេះជួសជុលដែរ?

ឡាយៈ អត់ចេះទេ កាលហ្នឹងមកគេឲ្យកាន់អញ្ចឹងហ្នឹង ។

សេងគាៈ អ្នកណាអ្នកឲ្យកាន់? រិទ្ធ ហ្នឹងអ្នកឲ្យកាន់មែន?

ឡាយៈ បាទ!

សេងគាៈ ហើយប្រធានកសិកម្មហ្នឹងឈ្មោះអីគេ?

ឡាយៈ ឈ្មោះ យ៉ូម តែមិនដឹងស្អី យ៉ូម ទេ ។

សេងគាៈ ហើយដល់ពេលគេឲ្យកាន់នៅធ្វើហ្នឹងរហូតទៅ?

ឡាយៈ បាទ! ទទួលខុសត្រូវផង រៀនផង ។

សេងគាៈ រហូតដល់ឆ្នាំ៧៨?

ឡាយៈ រហូតដល់ពួកនារតីចូលមក ។

សេងគាៈ ចុង៧៧ ឬ៧៨កាលហ្នឹង?

ឡាយៈ កាលយួនចូលមកឆ្នាំប៉ុន្មាន?

សេងគាៈ ឆ្នាំ៧៩ ដើម៧៩ ។

ឡាយៈ អញ្ចឹង៧៨ ខែកក្កដា ។

សេងគាៈ គេបញ្ជូនពួកនារតីមក?

ឡាយៈ បាទ!

សេងគាៈ ហើយគេបញ្ជូនមកកាន់កាប់ហ្នឹងគេធ្វើអីខ្លះ?

ឡាយៈ មកហ្នឹងចាប់ហ្នឹង ។

សេងគាៈ មកចាប់ពួកណាខ្លះ?

ឡាយៈ ចាប់ពួកដែលទទួលខុសត្រូវនៅហ្នឹង ភាគច្រើនគេចាប់សឹងតែទាំងអស់ហ្នឹង ។

សេងគាៈ គេចាប់យកទៅណាពូ?

ឡាយៈ ចាប់បាត់ៗ មិនដឹងថាគេចាប់យកទៅណាទេ ។

សេងគាៈ ចុះនៅពេលដែលចាប់បាត់ៗ ហើយនៅជិតភូមិពូ ពូបានដឹងក៏គេចខ្លួនទៅ?

ឡាយៈ ខ្ញុំចេះតែគេចៗទៅ ហើយបានប្រជាជនគេជួយលាក់ផង ហើយគេចទៅក៏បានរួចខ្លួនទៅ

សេងគាៈ ទាល់តែវៀតណាមចូលមកបានចាប់ខ្លួនពូម្តងទៀត?

ឡាយៈ បាទ!

សេងគាៈ តែគេមានវ៉ៃដំអីទេពូ?

ឡាយៈ គេអត់វ៉ៃទេ ។

សេងគា: អញ្ចឹងខ្ញុំសុំបកក្រោយបន្តិច ទាក់ទងនឹងរឿងពូធ្វើទាហានហ្នឹងមានត្រូវគ្រាប់ត្រូវអីទេ មានត្រូវរបួសត្រូវអីទេកាលហ្នឹង?

ឡាយ: កាលធ្វើខ្មែរក្រហមហ្នឹង?

សេងគា: បាទ!

ឡាយ: ត្រូវ ។

សេងគា: ត្រូវភ្នែកហ្នឹងមែន?

ឡាយ: ត្រូវក្បាលលើនេះទេ តែយូៗទៅវាទាញ ហើយមានត្រូវដៃដែរ ។

សេងគា: កាលហ្នឹងនៅឆ្នាំណាដែលពូត្រូវហ្នឹង?

ឡាយ: ត្រូវកាលឆ្នាំ៧៣ ។

សេងគា: កាលហ្នឹងត្រូវគ្រាប់កាំភ្លើងឬក៏ត្រូវមីន?

ឡាយ: កាលហ្នឹងត្រូវគ្រាប់សាវ៉ែន ។

សេងគា: ត្រូវចំដៃ?

ឡាយ: បាទ!

សេងគា: ហើយចុះក្បាល?

ឡាយ: ក្បាលហ្នឹងអត់មានស្នាមទេ គ្រាន់តែឈាម ។

សេងគា: អាហ្នឹងត្រូវឆ្នាំណា ជាមួយគ្នាមែនកាលហ្នឹង ។

ឡាយ: ត្រូវជាមួយគ្នា ។

សេងគា: ត្រូវចំដៃនឹងក្បាល?

ឡាយ: ហ្នឹងអើយ ។

សេងគា: កាលហ្នឹងទៅប្រយុទ្ធនៅសៀមរាបហ្នឹងមែន?

ឡាយ: អត់ទេ វ៉ៃនៅនេះ វ៉ៃប្រហែលជាមួយខែជាង ។

សេងគា: ហើយកាលហ្នឹងមានចាប់បានឈ្លើយសឹកខាង លន់ នល់ អីទេ ។

ឡាយ: កាលដែលខ្ញុំរបួសហ្នឹងអត់ទាន់បានបែកទេ ទើបតែវ៉ៃបានជាងមួយខែ ហើយខ្ញុំទៅពេទ្យទៅហើយដល់ពេលបែកទៅមិនដឹងថាមនុស្សហ្នឹងគេយកទៅខាងណាអីខាងណា ខ្ញុំអត់ដឹងទេ ។

សេងគា: ហើយកាលពូនៅអត់ទាន់បែកគេចាប់អត់ទាន់បានទេ?

ឡាយ: នៅកំពុងតែវ៉ៃគ្នានៅឡើយ ។

សេងគា៖ ហើយពូដេកពេទ្យនៅណាទៅ?

ឡាយ៖ ខ្ញុំដេកពេទ្យព្រៃធំហ្នឹងឯង ។

សេងគា៖ កាលហ្នឹងដេកបានប៉ុន្មានបានជា?

ឡាយ៖ យូដែរ ជិតមួយខែដែរហ្នឹង ។

សេងគា៖ ដល់ពេលជាហើយគេឲ្យទៅវៃទៀត?

ឡាយ៖ បាទ!

សេងគា៖ កាលហ្នឹងម៉េចបានជាត្រូវគ្រាប់ពូ?

ឡាយ៖ វាវៃទល់មុខគ្នា ហើយត្រូវគ្រាប់ផ្លោង ។

សេងគា៖ តែប្រធានហ្នឹងនៅរស់ឬក៏ស្លាប់ហើយ?

ឡាយ៖ ស្លាប់ហើយ ។

សេងគា៖ ស្លាប់ដោយសារអី?

ឡាយ៖ គេយកទៅសម្លាប់ចោល ។

សេងគា៖ កាលហ្នឹងគាត់បញ្ជូនពូមកវិញហើយនូវ?

ឡាយ៖ ចប់ហើយ កាលហ្នឹងឆ្នាំ៧៦ហើយហ្នឹងបានគេសម្លាប់ គាត់ធ្វើមេបញ្ជាការយូហើយ ហើយគ្រាន់តែខុសប៉ុណ្ណឹងក៏យកទៅវៃចោល ។

សេងគា៖ ដល់ពេល៧៩យួនចូលមកហើយក៏ចាប់ពូទៅ?

ឡាយ៖ បាទ!

សេងគា៖ ហើយគ្រួសាររបស់ពូអីគេអត់ដែលវាយធ្វើបាបទេ?

ឡាយ៖ អត់ដែលទេ ។

សេងគា៖ ហើយពេលដែលយួនចូលមកចាប់?

ឡាយ៖ បាទ!

សេងគា៖ ហើយពេលដែលចាប់ហ្នឹងគេមានធ្វើបាបពូដែលទេ?

ឡាយ៖ អត់ ។

សេងគា៖ គេចាប់យកទៅណាពូ?

ឡាយ៖ ចាប់យកទៅដាក់កន្លែងក្បាលស្ពានថ្មថ្មី កន្លែងខាងលិចផ្លូវ ។

សេងគា៖ ហើយពេលដែលចាប់ហ្នឹងគេដាក់ឃុំខ្លួនឬក៏ធ្វើយ៉ាងម៉េច?

ឡាយ៖ អត់ទេ គេលែងយើងឲ្យដើរធម្មតា ហើយបាយអីយើងដាំហូបធម្មតា ។

សេងគា: ហើយគេមានសួរអីទេក្រៅពីចាប់ហ្នឹង?

ឡាយ: អត់មានសួរអីទេ គ្រាន់តែគេយកទៅទុកហ្នឹង ។

សេងគា: ហើយទាល់តែប៉ុន្មានថ្ងៃទៅបានប្រជាជនផ្ដិតមេដៃទាមទារយកវិញ?

ឡាយ: ៥ថ្ងៃ ។

សេងគា: ៥ថ្ងៃហ្នឹងប្រជាជននាំគ្នាផ្ដិតមេដៃទាមទាយកមកវិញទៅ ហើយគេក៏ឲ្យមកវិញទៅ?

ឡាយ: បាទ!

សេងគា: ហើយទាក់ទងនឹងបងប្អូនពូដែលស្លាប់ តើពូមានដឹងថាគាត់ស្លាប់ដោយសារអី ហើយស្លាប់នៅកន្លែងណាទេ មានដឹងថាគាត់ខុសអីទេកាលហ្នឹង?

ឡាយ: អត់ដឹងរឿងទេ កាលហ្នឹងគាត់ទ័ពដែរហ្នឹង បងខ្ញុំ២នាក់ហ្នឹងទ័ពដែរហ្នឹង មួយខ្ញុំដឹងកន្លែងស្លាប់ គឺស្លាប់នៅកន្លែងបណ្ដាក់ ហើយមួយទៀតស្លាប់នៅតំបន់៤ ។

សេងគា: ប៉ុន្តែមានស្រី២នាក់ដែលស្លាប់ ប្រុស២ ស្រី២?

ឡាយ: បាទ!

សេងគា: ហើយឈ្មោះ ឌី កងទ័ពដែរ?

ឡាយ: បាទ!

សេងគា: បាត់ខ្លួនហ្នឹងឬក៏ម៉េច?

ឡាយ: ស្លាប់ហ្នឹង ។

សេងគា: ម៉េចបានពូដឹង?

ឡាយ: គេបាញ់ ។

សេងគា: កាលហ្នឹងនៅទ័ពជាមួយពូដែរឬក៏នៅផ្សេងគ្នា?

ឡាយ: ទ័ពដូចគ្នា តែនៅផ្សេងគ្នា ។

សេងគា: តែដល់ពេលស្លាប់ពូមានឃើញសាកសពដែរ?

ឡាយ: អត់មានឃើញទេ ។

សេងគា: តែគេមកប្រាប់?

ឡាយ: គេគ្រាន់តែប្រាប់ថាកប់នៅកន្លែងណាៗ តែទៅរកម៉េចនឹងឃើញ ។

សេងគា: កាលហ្នឹងពីណាគេអ្នកប្រាប់ពូ?

ឡាយ: ស្លាប់បាត់ហើយ ។

សេងគា: ឈ្មោះអីគេ ។

ឡាយៈ ឈ្មោះ វ៉ាត់ ។

សេងគាៈ គាត់ធ្វើទាហានជាមួយបងរបស់ពូមែន?

ឡាយៈ បាទ!

សេងគាៈ កាលហ្នឹងស្លាប់នៅឆ្នាំណាពូ?

ឡាយៈ ស្លាប់កាលយួនជិតចូល មិនមែនទេយួនចូលមកហើយ ។

សេងគាៈ អញ្ចឹង៧០ជាងហើយ ។

ឡាយៈ យួនចូលមកហើយបានគាត់ស្លាប់ កន្លែងហ្នឹងពេលដែលយួនចូលមកភ្លាមកន្លែងហ្នឹងយួនអត់អាចកាន់កាប់បានទេ ព្រោះវានៅជ្រៅ ។

សេងគាៈ យួនអ្នកបាញ់សម្លាប់ឬក៏ខ្មែរក្រហមគ្នាឯងអ្នកបាញ់សម្លាប់?

ឡាយៈ ខ្មែរក្រហមអ្នកបាញ់ ។

សេងគាៈ ម៉េចបានជាគេបាញ់ ពូមានដឹងទេ?

ឡាយៈ ខ្ញុំមិនដឹងថាគាត់មានកំហុសអីទេ ។

សេងគាៈ ចុះបងប្អូនពូ ស្រី២នាក់ទៀតឈ្មោះ ញ៉ែម នឹង ញ៉ែត នោះយ៉ាងម៉េចដែរ?

ឡាយៈ អាហ្នឹងស្លាប់ដោយសារអត់បាយ ។

សេងគាៈ ពីឆ្នាំណាដែរពូ?

ឡាយៈ ឆ្នាំ៧៧ ហើយឈ្មោះ លួន ហ្នឹងក៏គេសម្លាប់ ។

សេងគាៈ ហើយចុះប្អូនពូម្នាក់ទៀតដែលនៅរស់ កាលហ្នឹងគាត់នៅណាដែរ ។

ឡាយៈ សព្វថ្ងៃនៅអូរអំបិលយើងនេះ ។

សេងគាៈ តែកាលសម័យ ប៉ុល ពត?

ឡាយៈ កាលសម័យ ប៉ុល ពត នៅជុំជាមួយខ្ញុំនៅកំពីងពួយហ្នឹង មកពីកំពីងពួយ ហើយនៅដោយឡែកពីគ្នាមិនសូវបានជួបគ្នា ។

សេងគាៈ អាហ្នឹងគេហៅដើងព្រៃដូចគ្នា?

ឡាយៈ បាទ!

សេងគាៈ ព្រៃធំមែន?

ឡាយៈ ហ្នឹងអើយ ។

សេងគាៈ អញ្ចឹងកំពីងពួយគេហៅព្រៃធំដែរ?

ឡាយៈ អត់ទេ កំពីងពួយនៅខាងនោះព្រៃធំទេ ។

សេងគា៖ ហើយដល់ពេលនៅនោះរហូត ប្រពន្ធមាននៅកងខាងនោះជាមួយពូដែរ ខាងប្អូនពូ?
ឡាយ៖ អាហ្នឹងនៅផ្សេងគ្នាទៀត ។
សេងគា៖ អញ្ចឹងពេលដល់ឆ្នាំ៧០ ពូធ្វើអីទៀត?
ឡាយ៖ ដល់ពេលហ្នឹងឈប់ អត់មានធ្វើអីទេ ។
សេងគា៖ នៅផ្ទះធ្វើស្រែចំការ?
ឡាយ៖ ធ្វើស្រែធ្វើអីធម្មតា សម័យហ្នឹងគេដើររកស៊ីធម្មតា ។
សេងគា៖ ខ្ញុំភ្លេចសួរពូកន្លែងរៀបការ កាលពូរៀបការហ្នឹងឆ្នាំ៧០ ប៉ុន្មាន?
ឡាយ៖ កាលរៀបការហ្នឹងឆ្នាំ៧៦ ។
សេងគា៖ ពេលមកដល់ហ្នឹងគេឲ្យរៀបការ?
ឡាយ៖ បាទ!
សេងគា៖ កាលហ្នឹងអ្នកណាគេអ្នកចាត់តាំងឲ្យពូរៀបការ?
ឡាយ៖ ប្រធានកសិកម្មគេហ្នឹង ។
សេងគា៖ រៀបការហើយក៏ស្រលាញ់គ្នាមានកូនមានចៅទៅ?
ឡាយ៖ បាទ!
សេងគា៖ ចុះពូនៅហ្នឹងរហូតទាល់តែដល់ឆ្នាំ៩៦ បានរត់មកនេះ ឬក៏ម៉េច ៩០ ប៉ុន្មានបានពូរត់មកពីជំរុំ?
ឡាយ៖ យាយគេមកមុន ខ្ញុំមិនបានចាប់អារម្មណ៍ផង កាលហ្នឹងនៅខាងក្នុងគេអាល័យចាប់ទាហានអាញ៉ែអាញ៉ៅ ហើយកាលហ្នឹងខ្ញុំនៅរាងក្មេងដែរចេះតែគេចទៅ ។
សេងគា៖ ដល់គេចហើយក៏រត់មកដែរទៅ?
ឡាយ៖ គេទៅ យាយគេមកមុន ហើយខ្ញុំមកដែរ ។
សេងគា៖ មកហើយក៏នៅហ្នឹងរហូតទៅ?
ឡាយ៖ បាទ!
សេងគា៖ កាលមកនៅដំបូងមានគេបាញ់ប្រោះគ្នាទៀតទេ?
ឡាយ៖ មិនសូវមានទេ ។
សេងគា៖ ហើយកាលមកហ្នឹងសុទ្ធតែព្រៃមែនទេពូ?
ឡាយ៖ សូម្បីតែកន្លែងហាលខោអាវក៏អត់មានដែរ ។
សេងគា៖ ព្រៃសុទ្ធហ្នង?

ឡាយៈ ព្រៃសុទ្ធ ។

សេងគាៈ ហើយកាលហ្នឹងមកប៉ុន្មានគ្រួសារដែរពូ នៅនេះ?

ឡាយៈ នៅនេះសុទ្ធតែពួកខ្មែរក្រហមចាស់ហ្នឹង ពួកហ្នឹងគេនៅហ្នឹងស្រាប់ ។

សេងគាៈ បើតាមពូមើលទាំងអស់ប្រហែលប៉ុន្មានគ្រួសារក្នុងភូមិហ្នឹង?

ឡាយៈ ខ្មែរក្រហមមែន?

សេងគាៈ ទាំងខ្មែរក្រហម ទាំងពួកយើងមកនៅ?

ឡាយៈ ច្រើនដែរហ្នឹង មិនដឹងប៉ុន្មានរយព្រោះខ្ញុំមិនដែលបានសួរក្នុងភូមិផង អ្នកភូមិគេធ្លាប់ប្រាប់ដែរតែចេះតែភ្លេច ។

សេងគាៈ ហើយនៅនេះធ្វើស្រែចំការអីមួយទៀតទៅ?

ឡាយៈ រកស៊ីធម្មតា ធ្វើកម្មករ មានរបរអីរកខ្លួនឯងក៏មានទៅ បើអត់ក៏អត់ទៅ ។

សេងគាៈ អញ្ចឹងខ្ញុំចង់សួរពូមួយទៀត ទាក់ទងនឹងជុំវិញនេះ បើតាមគំនិតពូផ្ទាល់ដូចថាឥលូវនេះគេមានបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមធំៗអញ្ចឹង ប៉ុន្មានរូបនៅក្នុងតុលាការអញ្ចឹង តើពូមានអារម្មណ៍យ៉ាងម៉េចដែរ តើពូយល់ឃើញយ៉ាងម៉េចដែរ?

ឡាយៈ រឿងនេះបើតាមខ្ញុំស្មានប្រហែលជាមិនអាចកាត់កើតទេ គ្រាន់តែថាៗទៅមិនអាចកាត់ទេ ។

សេងគាៈ ប៉ុន្តែឥលូវវាមាននៅក្នុងតុលាការហើយ ។

ឡាយៈ មានហើយ?

សេងគាៈ បាទ! គេកាត់ទោស ឌុច ម្នាក់ហើយដែលជាប្រធានគុកទួលស្លែង ហើយមេគុកធំមជ្ឈិមណា៎ ហើយគេចាប់បាន ខៀវ សំផន, អៀង សារី, អៀង ធារិទ្ធ នឹង នួន ជា ពូធ្លាប់ឮឈ្មោះពួកហ្នឹងទេ?

ឡាយៈ ធ្លាប់ឮ ។

សេងគាៈ ហើយឥលូវគេចាប់បានហើយ ហើយគេហ្នឹងបើកសវនាការនៅចុងខែនេះទៀតហើយ អញ្ចឹងការកាត់ទោសពួកហ្នឹងពូយល់ឃើញយ៉ាងម៉េចដែរ បើតាមគំនិតរបស់ពូ?

ឡាយៈ អានេះវាពិបាកថាដែរ ព្រោះថាកាលពីមុនវាអត់មានតុលាការទេ ដល់ពេលឥលូវវាមានមិនដឹងថាច្បាប់ហ្នឹងវាញ៉ែកថាម៉េចអាហ្នឹង គេត្រូវធ្វើម៉េចធ្វើតាមគេទៅ ។

សេងគាៈ ចុះពូយល់ឃើញថាយ៉ាងម៉េចដែរនៅពេលកាត់ទោសមេដឹកនាំធំៗអញ្ចឹង ពូយល់ថាល្អ ឬក៏មិនល្អទេ ហើយពូគិតថាសាកសមគួរតែកាត់ទេ?

ឡាយៈ កំហុសពីមុនបើយកមកនិយាយវាគួតែកាត់ ។

សេងគាៈ អញ្ចឹងពូចង់ឲ្យកាត់ដែរ?

ឡាយៈ ចង់ ។

សេងគាៈ ហេតុអីបានជាពូគិតអញ្ចឹង?

ឡាយៈ ព្រោះពីមុនយើងបានធ្វើខុស ។

សេងគាៈ ហើយកាត់នេះក្នុងគោលបំណងគេគឺដើម្បីទប់ស្កាត់របបហ្នឹងកុំឲ្យមានទៀតណា៎ ហើយមួយទៀតដើម្បីឲ្យក្មេងៗបានដឹងបានរៀនសូត្រដើម្បីទប់ស្កាត់របបហ្នឹង ព្រោះក្មេងៗមួយចំនួនអត់ដឹងហើយអត់ជឿទៀត ។

ឡាយៈ បាទ!

សេងគាៈ អញ្ចឹងខ្ញុំអស់សំនួរដើម្បីសួរពូទៀតហើយ តើពូមានពាក្យពេជន៍អីដើម្បីចង់ប្រាប់នៅសំនួរដែលខ្ញុំមិនទាន់បានសួរទេ?

ឡាយៈ អត់មានទេ ។

សេងគាៈ អញ្ចឹងខ្ញុំសូមអរគុណពូច្រើន ។

ឡាយៈ បាទ!